D25042
(DC-Cam)

# មជ្ឈមណ្ឌលឯកសារកម្ពុជា

## សម្ភាសន៍ជាមួយ ហ៊ុម ហ៊ុយ
## នៅ ភូមិអន្លង់សាន ឃុំព្រែកស្បូវ ស្រុកកោះធំ ខេត្តកណ្ដាល
## នៅថ្ងៃទី ៤ ខែ មករា ឆ្នាំ ២០០២

ហ៊ុយៈ មានរឿងអីៗ ខ្ញុំអត់ដឹងគេ ចុះយើងមិនមែនអ្នកសួរគេទេ!

ឃីមៈ អញ្ចឹង?

ហ៊ុយៈ បាទ! ឯកសារនៅលើគេអ្នកសួរចំលើយ

ឃីមៈ តែតាមពិត ដឹងថាអ្នកហ្នឹងជាជនស្លូតត្រង់ដែរអត់ បើក្នុងចិត្តពូវិញហា៎? មើលទៅមាន អារម្មណ៍យ៉ាងម៉េចដែរ?

ហ៊ុយៈ ដឹងថាគេ ក៏ជាមនុស្សគ្មានរឿងអីធំៗដែរ ប៉ុន្តែគេចាប់

ឃីមៈ ចាស!

ហ៊ុយៈ បាទ! គេចាប់ដាក់គុកអញ្ចឹងទៅ

ឃីមៈ ចាស!

ហ៊ុយៈ គេយកទៅសំលាប់ចោលអញ្ចឹងទៅ យើងដឹងត្រឹមម៉ាបានដឹង

ឃីមៈ ចាស! ហើយចុះអារម្មណ៍ពូយ៉ាងម៉េចទៅ?

ហ៊ុយៈ អារម្មណ៍ដូចថា អារម្មណ៍យើងអាណិតអាសូរគេដែរ ដូចថានៅក្នុងមន្ទីរស២១ ដូចថា កម្មាភិបាលហើយនិងយុទ្ធជនដែលធ្វើការនៅកន្លែងហ្នឹងអញ្ចឹងហា៎

ឃីមៈ ចាស!

ហ៊ុយៈ ក៏គ្នាអត់ដឹង ថាខ្លួនគ្នាហ្នឹងត្រូវចាប់ ហើយមិនដឹងថាមានរឿងអី

ឃីមៈ ចាស! ហើយពូមានដែលជួបមុខឌុចហ៎? ឌុចប្រធាន

ហ៊ុយៈ អត់ដែលជួបទេ

ឃីមៈ ចុះនៅក្នុងមន្ទីរស២១អត់ដែលជួបហ៎!

ហ៊ុយៈ អ៎! កាលនៅហ្នឹងជួប

ឃីមៈ ជួប ហើយមុខគាត់យ៉ាងម៉េចទៅ? ស្លូតហ៎ ឬក៏មើលទៅកាច?

ហ៊ុយៈ ហ៎! មុខគាត់ស្លូត ប៉ុន្តែការងារអីគឺច្បាស់បោះគាត់

ឃីមៈ អញ្ចឹង?

ហ៊ុយៈ បាទ! អ្នកណាមួយក៏អត់ហ៊ានមើលមុខដែរ

ឃីមៈ ហើយគាត់មានមនោសញ្ចេតនាហ៎?

ហ៊ុយៈ មានមនោសញ្ចេតនាអី បើប្អូនខ្លួនឯងចាប់ដាក់គុកហើយ

ឃីមៈ អញ្ចឹង? ប្អូនឈ្មោះអី?

ហ៊ុយៈ ប្អូន២ នាក់គេចាប់ដាក់គុក

ឃីមៈ ចុះមានស្រីៗច្រើននាក់ដែរចូលកន្លែងហ្នឹង?

ហ៊ុយៈ ប្អូនស្រីគាត់នៅធ្វើការនៅកន្លែងហ្នឹងដែរ

ឃីមៈ អញ្ចឹង! ប្អូនស្រីគាត់មានទោសអី?

ហ៊ុយៈ មិនដឹងមានរឿងអី

ឃីមៈ អ៊ូ!

ហ៊ុយៈ ដល់អញ្ចឹងយើងមិនខ្លាច

ឃីមៈ ប្អូនគេហ្នឹងស្លាប់? ប្អូនហ្នឹងស្លាប់ហ៎?

ហ៊ុយៈ ប្អូនថ្លៃគាត់ហ្នឹង

ឃីមៈ ឈ្មោះអី?

ហ៊ុយៈ មិនដឹងឈ្មោះអីៗទេ ភ្លេចអស់ហើយ

ឃីមៈ អ៎!

ហ៊ុយៈ ចាប់ប្អូនថ្លៃឯងដាក់គុកអញ្ចឹងដល់ពួកខ្ញុំឃើញ ត្រូវតែត្រូវភ័យគេខ្លាច

ឃីមៈ ចាស!

ហ៊ុយៈ ប្អូនគេ គេចាប់ដាក់គុកទំរាំតែយើងមិនមែនបងប្អូនគេ

ឃីមៈ ចាស!

ហ៊ុយៈ មិនដឹងគេយកដាក់គុកឯណា

ឃីមៈ អ៎! អញ្ចឹងអត់ចាំឈ្មោះប្អូនស្រីហ្នឹងហ៎ណ៎?

ហ៊ុយៈ ប្អូនប្រុស

ឃីមៈ ប្អូនប្រុសហ៎?

ហ៊ុយៈ ប្អូនថ្លៃ

ឃីមៈ ចុះថាមានប្អូនស្រីមួយ?

ហ៊ុយៈ ប្អូនស្រីនៅធ្វើការនៅហ្នឹង ប្រពន្ធ

ឃីមៈ អ៎! យល់ហើយប្អូនស្រីហ្នឹងប្អូនឌុចហ្នឹង

ហ៊ុយៈ បាទ!

ឃីមៈ ចាប់ហ្នឹងចាប់បួនថ្ងៃ

ហ៊ុយៈ ចាប់បួនថ្ងៃ

ឃីមៈ ចុះប្អូនបង្កើតអត់មានចាប់ណាហ្អី នៅធ្វើការនៅហ្នឹងតើហ្អី?

ហ៊ុយៈ ប្អូនបង្កើតនៅ ចាប់បួនថ្ងៃដូចចាប់ប្អូនបង្កើតហ្នឹង

ឃីមៈ ចាស!

ហ៊ុយៈ បើប្អូនរបស់ខ្លួនឯងហើយ

ឃីមៈ អ៎!ប្រហែលគេឆ្លើយដាក់ អីដឹង?

ហ៊ុយៈ បាទ! មានគេឆ្លើយដាក់

ឃីមៈ ហើយប្អូនស្រីគាត់ធ្វើការអីនៅក្នុងគុកហ្នឹង?

ហ៊ុយៈ ធ្វើការអី មិនដឹងធ្វើការអីទេ

ឃីមៈ ចុះឥលូវរស់ក៏ស្លាប់?

ហ៊ុយៈ មិនដឹង

ឃីមៈ ប្អូនស្រីហ្នឹង?

ហ៊ុយៈ មិនដឹង ព្រោះបែក

ឃីមៈ ដឹងស្រុកកំណើតហេ៎?

ហ៊ុយៈ នៅកំពង់ធំ

ឃីមៈ នៅកំពង់ធំហេ៎ អ៎! ចុះកម្មាភិបាលស២១ស្រីៗមានហេ៎? មានស្រីៗហេ៎?

ហ៊ុយៈ អត់មានទេ! មានតែប្រពន្ធឌុច

ឃីមៈ ប្រពន្ធឌុចឈ្មោះអី?

ហ៊ុយៈ មិនដឹងឈ្មោះអីទេ

ឃីមៈ ហើយគេធ្វើអីគេ?

ហ៊ុយៈ គាត់ប្រធានពេទ្យ ប្រធានពេទ្យអីហេ៎ភ្លេចហើយ

ឃីមៈ អញ្ចឹងគាត់ប្រធានពេទ្យដែរអញ្ចឹង?

ហ៊ុយៈ បាទ!

ឃីមៈ អ៎!

ហ៊ុយៈ ប្រធាននារីពេទ្យហា៎

ឃីមៈ នៅក្នុងភ្នំពេញឬក៏នៅក្នុង ស ២១?

ហ៊ុយៈ នៅក្នុងភ្នំពេញហ្នឹង

ឃីមៈ អញ្ចឹង?

ហ៊ុយៈ ហើយគាត់ទៅដេកទៅនៅតែជាមួយឌុចហ្នឹង

ឃីមៈ អញ្ចឹង?

ហ៊ុយៈ ដល់ម៉ោងគេទៅធ្វើការ គេនៅកន្លែង

ឃីមៈ ដេកនៅទួលស្លែងហ្នឹងហ៎?

ហ៊ុយៈ បាទ!

ឃីមៈ អ៎! ហើយមានចាំទេថា មន្ទីរពេទ្យនៅម្តុំណា? គ្រាន់តែថាម្តុំណាទៅបានហើយ

ហ៊ុយៈ ហ៎! ពេទ្យអីគេទេ ខ្ញុំអត់ដែលស្គាល់ អត់ដែលទៅឃើញកន្លែងគាត់នៅដែរ ពេទ្យ៩៨ ម៉េចមិនដឹងទេ

ឃីមៈ អ៎! ពេទ្យ៩៨ ពេទ្យកងទ័ព

ហ៊ុយៈ បាទ!

ឃីមៈ ហើយមានដឹងថាឈ្មោះអីទេ ពូរនឹកមើល?

ហ៊ុយៈ ប្រពន្ធមិនដឹងឈ្មោះអី

ឃីមៈ ប្រពន្ធឌុចហ៎? ចំណាស់ណាកាលនុង?

ហ៊ុយៈ ហ៎! អាយុខ្ទង់ប្រហែលចូល៤០ ហើយ

ឃីមៈ ហើយគាត់មានកូនប៉ុន្មាន?

ហ៊ុយៈ កូន ២ នាក់ហ្អីមិនដឹង

ឃីមៈ ហើយកូនហ្នឹងធ្វើអី កូនឌុច?

ហ៊ុយៈ កូននៅតូចៗ

ឃីមៈ អញ្ចឹង! ប៉ុនណា?

ហ៊ុយៈ គាត់ទើបតែរៀបដែរ

ឃីមៈ អ៎! រៀបសម័យអាពតហ្នឹងដែហ៎?

ហ៊ុយៈ បាទ!

ឃីមៈ ស្អាតទេប្រពន្ធឌុច?

ហ៊ុយៈ ខ្មៅហើយធាត់

ឃីមៈ អត់ស្អាតទេ?

ហ៊ុយៈ សតែធ្មេញហ៎

ឃីមៈ អ៎!

ហ៊ុយៈ សតែធ្មេញហើយនិងភ្នែកហ៎

ឃីមៈ ហើយឌុចអគ្គការរៀបឲ្យដែរហ៎?

ហ៊ុយៈ បាទ!

ឃីមៈ ឈ្មោះអីគេ ខ្ញុំចង់ដឹងឈ្មោះ? ហើយចុះថាស្ទីគេ ម្នាក់មួយទៀតស្រីហ៎ា នៅកោះធំគេថា ធ្វើការស-២១ដែរ?

ហ៊ុយៈ អត់

ឃីមៈ ឈ្មោះអីគេ? ថាស្រវឹងស្រា

ជិតខាងៈ ទុយ គិន

ឃីមៈ អ៎! ទុយ គិន ៗ ទុយ គិនហ្នឹងនៅជាមួយពូដែរ?

ហ៊ុយៈ អត់!

ឃីមៈ គាត់នៅឯណាទៅ ទុយ គិនហ្នឹង?

ហ៊ុយៈ ប្រហែលនៅស្រែ

ឃីមៈ នៅស្រែហ៎! អត់ទេចង់និយាយពីសម័យខ្មែរក្រហមហ៎ា?

ហ៊ុយៈ អត់ អត់ដែលស្គាល់

ឃីមៈ ចុះមានស្រីៗហ៎ ក្រៅពីពួកស្រីៗ...នៅក្នុងមន្ទីរស-២១

ហ៊ុយៈ មានតែប្រពន្ធគេប៉ុន្មាននាក់ហ្នឹង

ឃីមៈ ប្រពន្ធណាគេខ្លះ?

ហ៊ុយៈ ប្រពន្ធនៃ.....

ឃីមៈ ខ្ញុំឃើញក្នុងឯកសារហ៎ា ០៣ ណាគេ?

ហ៊ុយៈ មិនដឹងអ្នកណា

ឃីមៈ ០៣ ០៧ នៅក្នុងមន្ទីរស-២១ គេហៅបង០៣ ០៣ ហ៎ា?

ហ៊ុយៈ អត់មានហ៎

ឃីមៈ ចុះ០៧?

ហ៊ុយៈ អត់មាន

ឃីមៈ អញ្ចឹងអត់ដែលឮហ៎?

ហ៊ុយៈ បាទ!

ឃីមៈ អ៎! ហើយប្រពន្ធកម្មាភិបាលនៅមន្ទីរស-២១ ភាគច្រើនគេធ្វើអីខ្លះពូ?

ហ៊ុយៈ ហ៎! មានតែប្រពន្ធខុចហ្នឹង ធ្វើប្រធានពេទ្យ៩៨ ហ្នឹង

ឃីមៈ ចាស!

ហ៊ុយៈ ហើយប្រពន្ធគាត់ហា ធ្វើអីហ៎

ឃីមៈ នៅក្នុងមន្ទីរហ្នឹងដែរ?

ហ៊ុយៈ ប្រពន្ធគាត់ហា ដូចនៅកន្លែងគាត់ដែរ

ឃីមៈ អញ្ចឹង! ប្រធានគេដែរ ហ្អីអត់ហ៎?

ហ៊ុយៈ គាត់សុទ្ធតែប្រធាន

ឃីមៈ គាត់ដេរកន្លែងណាពូ?

ហ៊ុយៈ គាត់ដេរអាខាងត្បូងស-២១

ឃីមៈ កន្លែងណា? ជាប់កន្លែងណា?

ហ៊ុយៈ គេហៅអីគេភ្លេច

ឃីមៈ ស្រី១ គាត់មកគាត់ដេរហ៎?

ហ៊ុយៈ បាទ!

ឃីមៈ កន្លែងណាត្រូវតែឈ្មោះ?

ហ៊ុយៈ អាកន្លែងអីវត្តទួលទំពូង

ឃីមៈ វត្តទួលទំពូងហ៎?

ហ៊ុយៈ អាតាមផ្លូវ

ឃីមៈ មានតែវត្តទួលទំពូងមួយ នៅម្តុំណា?

ហ៊ុយៈ អត់ទេ នៅតាមផ្ទះ

ឃីមៈ អញ្ចឹង?

ហ៊ុយៈ គាត់ដេរ គេបើកកន្លែងគាត់ដេរនៅហ្នឹងតាហ្នង

ឃីមៈ អ៎! ហើយពូកាលហ្នឹង

ហ៊ុយៈ ជាធានីគាត់ដេរ

ឃីមៈ ហើយពូកាលហ្នឹងមានដែលឲ្យឈាមឲ្យអីគេហ៎? គេមានមកបូមឈាមអីហ៎?

ហ៊ុយៈ អត់មានហ៎

ឃីមៈ អត់ដែលហ៎! ចុះមានដឹងថាពួករោងចក្រ កម្មករក្នុងភ្នំពេញហ្នឹងហ៎មានផ្តល់ឈាមមាន
អីហ៎?

ហ៊ុយៈ មានតែអ្នកផ្តល់ឈាម គេឲ្យតែផ្តល់ឈាមហ្នឹងហ្នង

ឃីមៈ អញ្ចឹង! ចុះពូ?

ហ៊ុយៈ ខ្ញុំអត់មានទេ

ឃីមៈ ចុះគេថាក្នុងម៉ាភ្នំពេញហ្នឹងទាំងអស់ហ៎?

ហ៊ុយៈ អត់មាន

ឃីមៈ អញ្ចឹង! គេផ្តល់ឈាមយ៉ាងម៉េច?

ហ៊ុយៈ មាននារី នារីយុវជនអ្នកដែលថាឈាមល្អហ្នឹង គេអត់ឲ្យធ្វើអីទេ គេចិញ្ចឹមយកឈាម សំរាប់ផ្តល់ឲ្យអ្នករបួសអីអញ្ចឹងហ៎

ឃីមៈ អ៎! សំរាប់អញ្ចឹងតាហ្នឹងហេ៎?

ហ៊ុយៈ បាទ!

ឃីមៈ ចុះមានដឹងថានៅក្នុងភ្នំពេញ គេមានចិញ្ចឹមកុមារតូចៗហ៎ មានដឹងហេ៎?

ហ៊ុយៈ កុមារនៅតាមកងអគ្គភាពគេ

ឃីមៈ ហើយមានដឹងថា អគ្គការខ្ញុំពូសួរកាលខ្ញុំទៅសំភាសគេនៅតាកែវគេថាអញ្ចេះស្រីស្អាតៗ ទុកឲ្យរៀបការជាមួយជនជាតិចិនហ៎?

ហ៊ុយៈ មាន

ឃីមៈ មានឮនិយាយទេ? ដើម្បីប្រកាសយកូនយអីហ៎

ហ៊ុយៈ អត់មាន

ឃីមៈ ពូអត់ដឹងហេ៎! អគ្គាល់ការហ៎?

ហ៊ុយៈ អត់ហេ៎

ឃីមៈ ក្រៅពីមន្ទីរស-២១ហ៎ ពូមានដែលចូលពេទ្យភ្នំពេញហេ៎?

ហ៊ុយៈ អត់ហេ៎

ឃីមៈ មានដែលស្គាល់កន្លែងផលិតថ្នាំ ផលិតអីហេ៎?

ហ៊ុយៈ អត់! បើដេកពេទ្យ ដេកពេទ្យសម័យហ្នឹង

ឃីមៈ ចុះមានដឹងថាកន្លែងជ្រោយចង្វារគេធ្វើអីហេ៎?

ហ៊ុយៈ អត់ដឹង

ឃីមៈ អ៎! ដែលបានចេញម៉ោទេអញ្ចឹង?

ហ៊ុយៈ ចេញៗហើយ

ឃីមៈ ចុះថ្ងៃសៅរ៍ ថ្ងៃអាទិត្យ?

ហ៊ុយៈ គេអត់ឲ្យទេ ថ្ងៃណាក៏ពលកម្មដែរ កន្លែងហ្នឹង ដាំចេក ដាំអីណាចេះតែធ្វើហើយ

ឃីម: អញ្ចឹង?

ហ៊ុយ: បាទ!

ឃីម: ពលកម្មគេ

ហ៊ុយ: រចេញទៅណាក៏គ្មាន

ឃីម: ចុះមានបានចេញទៅមើលកុន មើលល្ខោនអី?

ហ៊ុយ: អត់មាន

ឃីម: ថ្ងៃសៅរ៍ ថ្ងៃអាទិត្យអី?

ហ៊ុយ: មានតែអាថ្ងៃ បុណ្យគេអីអញ្ចឹងបានគេឲ្យមើល

ឃីម: ចាស! គេមើលកុនរឿងអី? មានចាំហេ៎?

ហ៊ុយ: កុនមានអី មានតែរឿងច្បាំង រឿងទាហ៊ានអីហ្នឹង

ឃីម: ហើយចាំចំណងជើងកុនខ្លះហេ៎?

ហ៊ុយ: ហេ៎! ដឹងកុនអី

ឃីម: កុនខ្មែរយើងអីក៏កុនប្រទេសចិន?

ហ៊ុយ: កុនខ្មែរយើង

ឃីម: តួខ្មែរយើងហេ៎?

ហ៊ុយ: បាទ!

ឃីម: មានចាំទេតួ ថាណាគេតួ?

ហ៊ុយ: ទួអីគេថតតាមនេះហ្នឹង

ឃីម: ឯកសារហេ៎?

ហ៊ុយ: បាទ!

ឃីម: សកម្មភាពគេធ្វើស្រែធ្វើអីហ្នឹងហេ៎?

ហ៊ុយ: ហ្នឹងហើយ!

ឃីម: ខ្ញុំស្មានថាដឹងគោលការណ៍ ខ្ញុំទៅសំភាសគេហ៎ាគេប្រាប់ថា រើសនារីស្អាតៗអីទុកមួយដុំ សំរាប់ទៅ

ហ៊ុយ: អត់មានហេ៎

ឃីម: ចុះ៧៩ ម៉ោពូអត់មានពួសួរអីទេហេ៎

ហ៊ុយ: អត់

ឃីម: អញ្ចឹងអរគុណច្រើន